**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០៨៤/២៣ ក.ប/ស.ស.រ.ខ.ល

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមអ្នកនាំពាក្យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីសម្រេចលេខ០៦៤ ក.ប/ស.ស.រ.ខ.ល ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងមន្ត្រីខុទ្ទកាល័យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

បង្កើតក្រុមអ្នកនាំពាក្យរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំណុះខុទ្ទកាល័យរដ្ឋមន្ត្រីដើម្បីធ្វើជាសេនាធិការលើកិច្ចការព័ត៌មានរបស់រដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **កត្តា អ៊ីន** | រដ្ឋលេខាធិការ | អ្នកនាំពាក្យ |
| ២. លោកជំទាវ | **ឃុន ណៃហៀក** | អនុរដ្ឋលេខាធិការ | អ្នកនាំពាក្យរងទី១ |
| ៣. ឯកឧត្តម | **ស៊ឹន មេសា** | ទីប្រឹក្សាក្រសួង និងជាអនុពន្ធសារព័ត៌មាន | អ្នកនាំពាក្យរងទី២ |
| ៤. ឯកឧត្តម | **ហេង សុផាន់ណារិទ្ធ** | អគ្គនាយករងបេឡាជាតិសន្តិសុខសង្គម | អ្នកនាំពាក្យរងទី៣ |
| ៥. ឯកឧត្តម | **សុខ សុគន្ធា** | ទីប្រឹក្សាក្រសួង | លេខាធិការ |

**ប្រការ២ .-**

ក្រុមអ្នកនាំពាក្យមានភារកិច្ចដូចខាងក្រោម៖

- សហការជាមួយគ្រប់អង្គភាព និងមន្ទីរក្រោមឱវាទក្រសួង ដើម្បីគ្រប់គ្រងនូវព័ត៌មាន និងដើម្បីឆ្លើយ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

បំភ្លឺជាមួយសាធារណជន និងបណ្ដាញសារព័ត៌មាន

- ទំនាក់ទំនង និងឆ្លើយឆ្លងផ្លូវការជាមួយអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ តាមរយៈតេលេក្រាមលេខ ០៩៨ ២១៣ ៣៦៩
- រៀបចំចេញសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួង ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា
- រៀបចំសន្និសីទសារព័ត៌មាននានារបស់ថ្នាក់ដឹកនាំក្រសួង ផលិតឯកសារវីដេអូអំពីសមិទ្ធផល និងស្នាដៃនានារបស់ក្រសួង ដើម្បីផ្សព្វផ្សាយ
- ធ្វើការផ្សព្វផ្សាយឱ្យបានទាន់ពេលវេលានូវសេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការណ៍ សេចក្តីជូនដំណឹង និងឯកសារវីដេអូនានា តាមរយៈប្រព័ន្ធផ្សព្វផ្សាយរបស់ក្រសួង៖
  - គេហទំព័រ ៖(https//www.mlvt.gov.kh/)
  - ហ្វេសប៊ុកផេក ៖ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (https://www.facebook.com/mlvt.gov.kh)
  - ឆាណែលតេឡេក្រាម ៖ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (https://t.me/molvtkhmer)
- ស្រាវជ្រាវ ចងក្រង ប្រមូល និងរក្សាទុកព័ត៌មានជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងកិច្ចការរបស់ក្រសួង
- បំពេញភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃគ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសាមីខ្លួនមានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ